ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែកក្កដា ឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែកក្កដា ឆ្នាំ២០២០នេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាធ្វើការដាំដុះបានចំនួន ២ ២៨១ ៩២១ហ.ត ស្មើនឹង៨៨,១៧% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត។ រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេស បទល្មើសព្រៃឈើ បទល្មើសជលផលក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែកក្កដា ឆ្នាំ២០២០នេះ គឺបានរៀបចំកិច្ចប្រជុំសំខាន់ៗ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២០ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងខែកក្កដា ឆ្នាំ២០២០នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាគិតត្រឹមថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៤៤៧ ៤៥៧ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១៨ ៣៤៤ហ.ត និងដោយគ្រឿងយន្តមានចំនួន ២ ៤២៩ ១១៣ហ.ត លើសឆ្នាំមុនចំនួន ២៣៥ ៧១៣ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ១៣ ០០១ហ.ត តិចជាងឆ្នាំមុនចំនួន ៣ ៩១៣ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ២៨១ ៩២១ហ.ត ស្មើនឹង៨៨,១៧% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត លើសឆ្នាំមុនចំនួន ១៦៤ ៣២៧ហ.ត។

#### ១.២ ការប្រមូលផលស្រូវស្រាលដើមរដូវវស្សា

ការប្រមូលផលស្រូវស្រាលសម្រេចបានចំនួន ៦៣ ៧៧៦ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ២៦៧ ៦៩៦តោន លើសឆ្នាំមុនចំនួន ១០៣ ៩៤២តោន និងទទួលបានទិន្នផលគិតជាមធ្យម ៤,១៩៧តោន/ហ.ត។

#### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវវស្សា

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៤៩ ៥២៤ហ.ត ស្មើនឹង១០០,២០% នៃផែនការចំនួន ៤៩ ៤២៤ហ.ត លើសឆ្នាំមុនចំនួន ៧ ០៣២ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៧៣២ ៣៨៩ហ.ត ស្មើនឹង៨៣,៧៤% នៃផែនការចំនួន ៨៧៤ ៥៩៥ហ.ត លើសឆ្នាំមុនចំនួន ១១ ២៥៧ហ.ត។

### ១.៤ ស្ថានភាពប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ

ដំណាំស្រូវនៅខេត្តចំនួន ៩កំពុងរងផលប៉ះពាល់ និងខូចខាតដោយគ្រោះរាំងស្ងួត ដោយទទួលរងផលប៉ះពាល់សរុបចំនួន ១០២ ៤៨៤ហ.ត ស្មើនឹង៨,៥៤%។ តាមការវាយតម្លៃ ដំណាំស្រូវបានខូចខាតសរុបចំនួន ៣ ០០៦ហ.ត ស្មើនឹង២,៩៣% នៃផ្ទៃដីផលប៉ះពាល់សរុប។

### ១.៥ ការនាំចេញផលិតផលកសិកម្ម

១.៥.១ ការនាំចេញអង្ករ

បរិមាណនាំចេញអង្ករបានចំនួន ២៨ ៤១៣តោន កើនឡើងចំនួន ១ ៩៣៨តោន (+៧,៣២%) ច្រើនជាងបរិមាណនាំចេញក្នុងខែកក្កដា ឆ្នាំ២០១៩ ចំនួន ២៦ ៤៧៥តោន។ សរុបរយៈពេល៧ខែនាំចេញអង្ករបានចំនួន ៤២៦ ០៧៣តោន និងនាំចេញទៅកាន់ទិសដៅចំនួន ៥៧ប្រទេស ក្នុងនោះប្រទេសចិនលំដាប់ទី១ (១៥៥ ៣២៧តោន) ប្រទេសបារាំងលំដាប់ទី២ (៥៤ ៤០០តោន) ប្រទេសហ្គាបុងលំដាប់ទី៣ (២៨ ៤៧១តោន) ប្រទេសម៉ាឡេស៊ីលំដាប់ទី៤ (២៣ ១៧៨តោន) ប្រទេសអូស្ត្រាលីលំដាប់ទី៥ (១៩ ៥៦៤តោន) ប្រទេសណេដឺឡែនលំដាប់ទី៦ (១៧ ៤៩០តោន) ប្រទេសវៀតណាមលំដាប់ទី៧ (១២ ៨៣៦តោន) ប្រទេសអង់គ្លេសលំដាប់ទី៨ (១១ ២៨១តោន) ប្រទេសប្រ៊ុយណេលំដាប់ទី៩ (១០ ៥០០តោន) និងប្រទេសប៉ូឡូញលំដាប់ទី១០ (១០ ០៦៥តោន) ហើយបច្ចុប្បន្នក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៧០ក្រុមហ៊ុន។

១.៥.២ ការនាំចេញផ្លែឈើ

បរិមាណនាំចេញផ្លែចេកស្រស់ប្រចាំថ្ងៃបានចំនួន ៦២៦,៧៨តោន សរុបរយៈពេល៧ខែចំនួន ១៦៦ ៤២៥,៩៥តោន ទៅកាន់ប្រទេសចិន វៀតណាម និងប្រទេសជប៉ុន។ ផ្លែស្វាយសរុបរយៈពេល៧ខែចំនួន ៤៦ ៣៤០,៥៦តោន ទៅកាន់ប្រទេសថៃ វៀតណាម បារាំង រុស្ស៊ី កូរ៉េ និងហុងកុង។ គ្រាប់ពោតប្រចាំថ្ងៃចំនួន ៦ ២៥០តោន សរុបរយៈពេល៧ខែចំនួន ១៤៤ ៧២១,៤៤តោន ទៅកាន់ប្រទេសថៃ កូរ៉េ និងតៃវ៉ាន់។

## ២ ផ្នែកផលិតកម្មកៅស៊ូ

២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ៧០១ហ.ត ក្នុងនោះ ផ្ទៃដីចៀរជ័រចំនួន ២៥០ ១០៧ហ.ត ស្មើនឹង៦២% និងផ្ទៃដីថែទាំចំនួន ១៥៤ ៥៩៤ហ.ត ស្មើនឹង៣៨%។

២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ២៨ ១៦៣តោន កើនឡើងចំនួន ២ ៤៦០តោន ស្មើនឹង១០% ធៀបខែមុន និងកើនឡើងចំនួន ៥ ៣០៥តោន ស្មើនឹង២៣% ធៀបខែកក្កដា ឆ្នាំ២០១៩។

២.៣ ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់សម្រេចបានចំនួន ២៥ ៩៥៣តោន កើនឡើងចំនួន ៥២៧តោន ស្មើនឹង២% ធៀបខែមុន និងកើនឡើង ៤ ៣៧០តោន ស្មើនឹង២០% ធៀបខែកក្កដា ឆ្នាំ២០១៩។

២.៤ តម្លៃកៅស៊ូ

- តម្លៃលក់មធ្យមក្នុងខែកក្កដា គឺ១ ២៧៥ដុល្លារ/តោន កើនឡើងចំនួន ៨៤ដុល្លារ/តោន ស្មើនឹង៧,០២% ធៀបខែមុន និងថយចុះចំនួន ១២១ដុល្លារ/តោន ស្មើនឹង៦,៦៨% ធៀបខែកក្កដា ឆ្នាំ២០១៩

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការក្នុងខែកក្កដា គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៤ ០៥០៛/គ.ក្រ ដល់ ៤ ៥០០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ១ ៨៥០៛/គ.ក្រ ដល់ ២ ២៧៥៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការងារព្រៃឈើ

- បានទាញយករូបភាពផ្កាយរណប (Sentinel2) ឆ្នាំ២០២០ ចំនួន ៥ផ្ទាំង សម្រាប់បន្តការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២០ និងកំពុងផ្ទៀងផ្ទាត់គម្របព្រៃឈើលើរូបភាពផ្កាយរណប (Sentinel2) ឆ្នាំ២០២០

- បានចេញសេចក្តីប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ៣កន្លែងស្ថិតក្នុងខេត្តកំពង់ធំ និងខេត្តក្រចេះចំនួន ២កន្លែងផ្ទៃដីសរុបទំហំ ១ ២៤៩,៥៨ហ.ត

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផលអនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ១ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន១នាក់ មានឈើហ៊ុបមូលសរុបចំនួន ១ ០៩៩ម៉$^{៣}$ និងជ័រទឹកចំនួន ៦០តោន។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- បានចុះអនុវត្តគម្រោងស្តីពីការគ្រប់គ្រង និងការពារតំបន់ទេសភាពព្រៃឈើជាំក្សាន្តនៅកម្ពុជាដោយវាយតម្លៃគម្របព្រៃឈើស្រុកជាំក្សាន្តខេត្តព្រះវិហារឆ្នាំ២០២០ បានចុះស្រាវជ្រាវស្ថានភាពសេដ្ឋកិច្ចសង្គម របស់សហគមន៍មូលដ្ឋាន

ដែលរស់ក្នុង និងក្បែរតំបន់ព្រៃនិងផលប៉ះពាល់លើអេកូឡូស៊ី និងទេសភាពព្រៃឈើជាំក្សាន្ត ព្រមទាំងចុះសិក្សាស្រាវជ្រាវសត្វព្រៃក្នុងតំបន់ព្រៃឈើស្រុកជាំក្សាន្តខេត្តព្រះវិហារ

- បានចេញលិខិតអនុញ្ញាតដឹកជញ្ជូនសត្វព្រៃជូនក្រុមហ៊ុនចំនួន ៧ច្បាប់ (ពន្យារពេល១ច្បាប់) មានស្វាក្ដាមចំនួន ៤ ៧០៤ក្បាល ក្នុងនោះដឹកជញ្ជូនក្នុងស្រុកចំនួន ៧៦០ក្បាល និងនាំចេញចំនួន ៣ ៩៤៤ក្បាល

- បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ៨ច្បាប់ ក្នុងនោះ ៧ច្បាប់ សម្រាប់ការថែរក្សាសត្វក្រៀលកកាំ និង ១ច្បាប់សម្រាប់ការថែរក្សាសត្វព្រៃប្រភេទផ្សេងទៀតមានទីតាំងនៅខេត្តកណ្ដាល តាកែវ កោះកុង និងរាជធានីភ្នំពេញ។

## ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន ៧មានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្ដាមយកកូននាំចេញចំនួន ៨កន្លែង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានសត្វស្វាក្ដាមចំនួន ៦៨ ០១៣ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៣ ៣១១ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៨៩៦ក្បាល(បក្សីចំនួន ៨៦ប្រភេទ ថនិកសត្វចំនួន ៤៦ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ៩១ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ៣៩ក្បាល ស្ដារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ៤២៨ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI បានល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥ គឺ អារ៉ែង ឆាយរាប តំបន់ស្ដារក្រពើស្ទឹងជាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- បានជួសជុលផ្លូវដោយក្រាលក្រួសក្រហមសរុបប្រវែង ២៦០ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ ០,៣៤ហ.តនៅក្នុងតំបន់សួនសត្វ។

## ៣.៤ ការងារដាំដើមឈើ

- បាននិងកំពុងថែទាំប្រឡាយប្រវែង ១៨ ០០០ម៉ែត្រ ក្នុងនោះប្រឡាយជីកឆ្នាំ២០១៨ ប្រវែង ១០ ០០០ម៉ែត្រ និងឆ្នាំ២០១៩ មានប្រវែង ៨ ០០០ម៉ែត្រនៅក្នុងខេត្តកំពង់ធំ និងខេត្តព្រះសីហនុ

- បាននិងកំពុងថែទាំចម្ការឈើសរុប ៩៣២ហ.ត ក្នុងនោះចម្ការពូជឈើ ៨៩ហ.ត ឡូត៍បង្ហាញកសិ-រុក្ខកម្ម ៤៩ហ.ត ចម្ការឈើដាំទំហំ ៧៥៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា ទំហំ ៤០ហ.ត នៅក្នុងខេត្តកំពត កណ្ដាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ

- បានដាំកូនឈើជាចម្ការទំហំ ១៥ហ.ត នៅស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំ និងឈូសឆាយសម្អាតផ្ទៃដីស្ថានីយដាំឈើម្សៅក្រដាស ហ៊ុន សែន មានក ខេត្តកំពង់ឆ្នាំងទំហំ ២៥ហ.ត

- បានបណ្ដុះកូនឈើគ្រប់ប្រភេទចំនួន ៥៧ ៦៨០ដើម ក្នុងនោះថ្នាលបណ្ដុះកូនឈើតាមបណ្ដាខណ្ឌរដ្ឋបាលព្រៃឈើនៅទូទាំងប្រទេសចំនួន ៤៥ ៤២០ដើម និងថ្នាលបណ្ដុះកូនឈើចំនួន ៦កន្លែង ក្នុងខេត្តចំនួន ៥មាន៖ ខេត្តពោធិ៍សាត់ កំពង់ធំ តាកែវ កំពង់ចាម និងខេត្តកណ្ដាល ២កន្លែង ចំនួន ១២ ២៦០ដើម និងបានប្រគេនកូនឈើដល់ព្រះសង្ឃ និងចែកជូនប្រជាពលរដ្ឋចំនួន ៦២ ១៥៦ដើម។

## ៣.៥ ការងារនីតិកម្មនិងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ១១៩ករណី ដោយពិន័យអន្តរការណ៍ចំនួន ៥៦ករណី និងបញ្ជូនទៅតុលាការចំនួន ៦៣ករណី

- ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមានឈើមូល-ជ្រុងចំនួន ៥ម$^{៣}$ ឈើអារចំនួន ១៧៤ម$^{៣}$ (ចំនួន ៩៨ករណី) ផ្ទៃដីព្រៃឈើបានកាប់រានទំហំ ៨៥ហ.ត (ចំនួន១២ករណី)៖ ខេត្តក្រចេះ ៣ករណី ស្ទឹងត្រែង២ករណី ព្រះសីហនុ២ករណី និងខេត្តព្រះវិហារ៥ករណី។ វត្ថុតាងសត្វព្រៃបានចាប់ឃាត់ចំនួន ៩២០ក្បាល និង ១១១គ.ក្រ និងអនុផលព្រៃឈើព្រមទាំងឧបករណ៍ សម្ភារផ្សេងៗទៀត។

## ៣.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- បានចុះពិនិត្យសិក្សាចំពោះសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផលអនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ១នៅខេត្តកំពង់ធំ

- បានពន្យារសុពលភាពរោងម៉ាស៊ីនអារកែច្នៃផលអនុផលព្រៃឈើចំនួន ១កន្លែង

- ក្រុមហ៊ុនចំនួន ៣បាននាំចេញផលិតផលរានទេវតា ឈើកែច្នៃ និងជ័រទឹកទៅក្រៅប្រទេសមានបរិមាណចំនួន ៩៨ម$^{៣}$ និងជ័រទឹកចំនួន ២០តោន

- ក្រុមហ៊ុនចំនួន ២បាននាំចូលឈើកែច្នៃមានបរិមាណចំនួន ១១៧ម$^{៣}$

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន ៣ក្រុមហ៊ុន មានបរិមាណឈើកែច្នៃសរុបចំនួន ៦០០ម៣ ឈើចិញ្ច្រាំ ឬកម្ទេចឈើ (ប្រេងខ្យល់) ចំនួន ៤ ០០០តោន និងឫស្សីកែច្នៃចំនួន ១២តោន

- បានផ្តល់ទិដ្ឋការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន ១ក្រុមហ៊ុន មានបរិមាណឈើកែច្នៃ (MDF,Wood Panel) សរុបចំនួន ២២៥ម៣ ។

**៣.៧ ការងារចំណូលព្រៃឈើ**

- បានចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួន ១ ២០៧ ៦៤៩ ២៨២រៀល និង៤៦៨ ៥៥៥,៣៦ ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្ទូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

**៤.២ ការងារសុខភាពសត្វ**

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៥ករណី និងរាជធានី-ខេត្តចំនួន ២៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១២ ៦២០លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចុះផ្សព្វផ្សាយស្តីពីការពិនិត្យកសិដ្ឋានចិញ្ចឹមសត្វ ដែលខ្វះខាតបច្ចេកទេសចិញ្ចឹមសត្វ និងការដាំដំណាំចំណីសត្វនៅខេត្តកំពង់ធំ។
- **ការងារនីតិកម្ម និងវិវាទ** បាននិងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តមួយចំនួនទៀត។

**៤.៣ ការងារស្រាវជ្រាវ**

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៧ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ១ ៩៧០វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

## ៥ ផ្នែកជលផល

**៥.១ អាជីវកម្មនេសាទ**

៥.១.១ នេសាទទឹកសាប

- ដាយត្រីបានបញ្ចប់ត្រឹមចំនួន ១ ៥០០តោន ស្មើនឹង១២,៥០% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០១៩ ថយចុះចំនួន ៨៧០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ១៩ ៣៥០តោន សរុបរយៈពេល៧ខែចំនួន ១៥២ ៣០០តោន ស្មើនឹង ៤៤,១៤%នៃផែនការចំនួន ៣៤៥ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០១៩ ថយចុះចំនួន ៣ ០០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៩ ៤០៦តោន សរុបរយៈពេល៧ខែចំនួន ៤០ ១៨៦តោន ស្មើនឹង ២៧,៧១% នៃផែនការចំនួន ១៤៥ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០១៩ ថយចុះចំនួន ១ ៩៤៤តោន។

៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ១០ ៥៥០តោន សរុបរយៈពេល៧ខែចំនួន ៦៧ ៧១០តោន ស្មើនឹង៦១,៥៥% នៃផែនការចំនួន ១១០ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០១៩ កើនឡើងចំនួន ២៦០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ៤៩ ០៧៥តោន សរុបរយៈពេល៧ខែចំនួន ១៨៤ ៤៩០តោន ស្មើនឹង ៥១,២៥% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០១៩ កើនឡើងចំនួន ៣០ ៧៤៨តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ៣៩ ០០០ក្បាល សរុបរយៈពេល៧ខែចំនួន ១៨១ ២៤០ក្បាល ស្មើនឹង៦០,៤១% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបខែកក្កដា ឆ្នាំ២០១៩ កើនឡើងចំនួន ២៤០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ៣៨ ០០០ ០០០កូន សរុបរយៈពេល៧ខែចំនួន ១២១ ៥០០ ០០០កូន ស្មើនឹង ៥០,៦៣% នៃផែនការចំនួន ២៤០ ០០០ ០០០កូន ប្រៀបធៀបខែកក្កដា ឆ្នាំ២០១៩ កើនឡើងចំនួនប្រមាណ ៥០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៥ ៨០០តោន សរុបរយៈពេល៧ខែចំនួន ៣៣ ០៥០តោន ស្មើនឹង៤០,៣០% នៃផែនការចំនួន ៨២ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០១៩ ថយចុះចំនួន ១ ៥០០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ៨៣០តោន សរុបរយៈពេល៧ខែចំនួន ៦ ៩៤០តោន ស្មើនឹង៧៧,១១% នៃផែនការចំនួន ៩ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០១៩ កើនឡើងចំនួន ៧០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ២ ៦០០ ០០០លីត្រ សរុបរយៈពេល៧ខែចំនួន ៣៨ ៥១២ ០០០លីត្រ ស្មើនឹង៧០,០២% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបខែកក្កដា ឆ្នាំ២០១៩ ថយចុះចំនួន ៧៨៨ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ១៨៩ករណី ប្រៀបធៀបខែកក្កដា ឆ្នាំ២០១៩ ថយចុះចំនួន ១៧១ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ១៧៤ករណី និងសមុទ្រចំនួន ១៥ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញក្នុងខែពុំមាន សរុបរយៈពេល៧ខែចំនួន ១ ១៤០តោន ស្មើនឹង៧,៦០% នៃផែនការចំនួន ១៥ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០១៩ ថយចុះចំនួន ៥ ០៦០តោន

- ផលនេសាទកែច្នៃនាំចេញក្នុងខែពុំមាន សរុបរយៈពេល៧ខែចំនួន ២៣២តោន ស្មើនឹង៤,៦៤% នៃផែនការចំនួន ៥ ០០០តោន ប្រៀបធៀបខែកក្កដា ឆ្នាំ២០១៩ ថយចុះចំនួន ៣ ២០៨តោន។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលបានចំនួន ១០៩ ១១៤ ០០០រៀល សរុបរយៈពេល៧ខែចំនួន ៤៥៥ ៣៩៨ ៣៦០រៀល ស្មើនឹង១៥,២១% នៃផែនការចំនួន ២ ៩៩៤ ០០០ ០០០រៀល ប្រៀបធៀបខែកក្កដាឆ្នាំ២០១៩ ថយចុះចំនួន ៧៨ ១៣៩ ៤៨៨រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- បានចុះត្រួតពិនិត្យលើការងារដឹកនាំ គ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពោធិ៍សាត់ កំពង់ឆ្នាំង កោះកុង ព្រះសីហនុ កំពង់ធំ ប៉ៃលិន និងខេត្តបាត់ដំបង និងជំរុញការកែលម្អចំណុចខ្វះខាតដែលក្រសួងចេញលិខិតឱ្យកែលម្អកន្លងមក

- បានទទួលពាក្យបណ្តឹងចំនួន ២ករណី

- ប្រព័ន្ធអ៊ិនធើណេតរបស់អគ្គាធិការដ្ឋានសម្រាប់ការទទួលពាក្យបណ្តឹងបានរៀបចំរួចរាល់អាចដំណើរការបានតាមគេហទំព័រឈ្មោះ www.gi.maff.gov.kh

- បានស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ១២៥ករណី

- បានចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ៦លើក។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៧៧៣ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ៣២៥ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៣០៤ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១៤៤ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១ ១០២ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៤១ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ១៦ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៨៧៤នាក់ (ស្រី១ ៤២៤នាក់) ស្មើនឹង២៤,២៤% រួមមាន៖
    + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩២៥នាក់ (ស្រី៨២៤នាក់) ស្មើនឹង២៨,១៧%
    + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩៤៩នាក់ (ស្រី៦០៣នាក់) ស្មើនឹង២០,៣៤%
- បានរៀបចំប្រកាសផ្ទេរមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន ១២នាក់ (ស្រី១នាក់)
- បានរៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារចំនួន ៥នាក់ (ស្រី៤នាក់) ក្នុងនោះមាន៖ ច្បាប់ឈប់សម្រាកព្យាបាលជំងឺចំនួន ១នាក់ និងច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ៤នាក់
- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យចូលបម្រើការងារវិញចំនួន ៣នាក់
- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ១០នាក់
- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ៦៥នាក់ (ស្រី១២នាក់) ក្នុងនោះ៖
    + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ៦០នាក់ (ស្រី១១នាក់)
    + ការបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ៥នាក់ (ស្រី១នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- បានចុះប្រមូលឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីដីជាដីឯកជនរបស់រដ្ឋក្នុងគោលដៅសម្បទានដីសេដ្ឋកិច្ចរបស់គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចនៅក្នុងខេត្តកំពង់ធំ
- អនុញ្ញាតជាគោលការណ៍ឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង បញ្ចេញស្រូវពូជ ចាស់អន់គុណភាព ចំនួន១០ ៦៣៣ គីឡូក្រាម
- បានធ្វើអង្កេតស្ទង់ទិន្នផលស្រូវស្រាលដើមរដូវឆ្នាំ២០២០ នៅខេត្តក្រចេះ និងតាកែវ
- បានពិនិត្យតាមដានការងារបង្កបង្កើនផលស្រូវស្រាលដើមរដូវឆ្នាំ២០២០
- បានចុះពិនិត្យតាមដានអំពីការស្រង់ព័ត៌មានតម្លៃទីផ្សារកសិកម្មនៅខេត្តបាត់ដំបង ប៉ៃលិន ឧត្តរមានជ័យ ព្រះវិហារ ព្រះសីហនុ កែប ស្ទឹងត្រែង និងខេត្តរតនគិរី
- បានការជំរុញសកម្មភាពការងារប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចបង់ចូលថវិការដ្ឋ
- បានចុះរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់បរិស្ថានដល់កសិករចំនួន ៣វគ្គ សរុបកសិករចំនួន ៨៩នាក់(ស្រី៤១នាក់) នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ
- បានពិនិត្យ កែសម្រួល និងធ្វើបច្ចុប្បន្នភាពមេរៀនសម្រាប់វគ្គបណ្តុះបណ្តាលដល់កសិករស្តីពីការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់បរិស្ថានក្នុងផលិតកម្មកសិកម្ម។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បានអនុវត្តប្រមូលចំណូលនូវទឹកប្រាក់សរុបចំនួន ៤ ៩០៨ ១១៥ ២៦២រៀល
- អង្គភាពប្រមូលចំណូលទាំង៦បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធNRMIS សរុបចំនួន ៣ ៩៩៩ ៩៣៣ ៨៩៩រៀល
- បានបញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបមានចំនួន ៦ ៦៥១ ៤០៨ ០៨៥រៀល
- បានរៀបចំដីកាអមបញ្ជូនស្តីពីសំណើសុំផ្តល់កិច្ចសហការខ្ពស់ក្នុងការកត់ត្រាចំណូលសម្បទានដីសេដ្ឋកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS)
- បានរៀបចំលិខិតសំណើសុំថវិកាចំនួន ១៦៥ ១៦៥,០០ដុល្លារអាមេរិក និងចំនួន ១០២ ៤៨០,០០អឺរ៉ូ ដើម្បីទូទាត់លើកទី២ ជូនក្រុមហ៊ុន Agriconsulting Europe S.A (AESA) សម្រាប់អនុវត្តកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកវារីវប្បកម្ម (Cap Fish Aquaculture)

- បានចូលរួមពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីគណនេយ្យឆ្នាំ២០១៩ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត កំពង់ចាម ក្រចេះ ត្បូងឃ្មុំ មណ្ឌលគិរី បាត់ដំបង ប៉ៃលិន កំពង់ឆ្នាំង និងខេត្តបន្ទាយមានជ័យ

- បានចុះពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៩ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់ កំពង់ចាម ក្រចេះ ត្បូងឃ្មុំ មណ្ឌលគិរី បន្ទាយមានជ័យ កំពង់ឆ្នាំង បាត់ដំបង និងខេត្តប៉ៃលិន

- បានរៀបចំឯកសារដេញថ្លៃការផ្គត់ផ្គង់ថ្នាំចាក់ការពារ និងព្យាបាលសត្វឆមាសទី២ ឆ្នាំ២០២០ របស់អគ្គនាយក-ដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

- បានចុះពិនិត្យ វាយតម្លៃបញ្ចប់សុពលភាពការងារជីកប្រឡាយការពារតំបន់ឈើដាំគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើនៅខេត្តកំពង់ធំ និងខេត្តព្រះសីហនុប្រចាំឆ្នាំ២០១៩។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានធ្វើសំណើសុំបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនឆ្នាំ២០២០ សម្រាប់រថយន្តចំនួន ២គ្រឿង
- បានធ្វើគម្រោងថវិកាកម្មវិធីសម្រាប់ឆ្នាំ២០២១ ក្នុងទម្រង់ P3 និង P4
- បានចុះធ្វើសវនកម្មតាមផែនការសកម្មភាពសវនកម្មផ្ទៃក្នុងបានចំនួន ៤សវនដ្ឋាន នៅនាយកដ្ឋានកិច្ចការរដ្ឋបាល វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងគម្រោងការគ្រប់គ្រងធនធានជលផលភូមិភាគឥសាន។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានចូលរួមកិច្ចប្រជុំចំនួន ១លើកក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី និងកិច្ចប្រជុំពីចម្ងាយចំនួន ៥លើក ក្រោមក្របខ័ណ្ឌអាស៊ាន
- ការងារក្រៅប្រទេសបានចូលរួមសិក្ខាសាលាតាមវីដេអូពីចម្ងាយចំនួន ១លើកក្រោមក្របខ័ណ្ឌអាស៊ាន
- បានសម្របសម្រួលរៀបចំកិច្ចប្រជុំនៅក្នុងប្រទេសចំនួន ១លើក
- បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសជប៉ុនស្តីពី Safe Vegetable Development for Domestic Market and Export ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី
- បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយ ADDA ស្តីពីគម្រោងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម និងសង្គមស៊ីវិលនៅខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២០ក្រុមហ៊ុន សរុបចំនួន ១៨៦មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៨ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៥ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣ក្រុមហ៊ុន។

### ១៣.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៨ក្រុមហ៊ុន សរុបចំនួន ៤៧សំណាក។

### ១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត

- បានប្រកាសអន្តរក្រសួងស្តីពីគោលការណ៍ណែនាំវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ថ្នាំកសិកម្ម ការបោះសំណល់ពីការប្រើប្រាស់ថ្នាំកសិកម្ម និងសំបកវេចខ្ចប់ថ្នាំកសិកម្ម
- បានបើកវគ្គអប់រំសមត្ថភាពវិជ្ជាជីវៈដល់អាជីវករ អ្នកលក់ដុំលក់រាយថ្នាំកសិកម្ម និងជីកសិកម្មនៅខេត្តកំពង់ធំ មានអ្នកចូលរួមចំនួន ១៤០នាក់។

### ១៣.៤ ការងារអនុវត្តច្បាប់

- ប្រកាសប្រតិវេទន៍ស្តីពីការនាំចូលថ្នាំកសិកម្ម និងជីកសិកម្មរបស់ក្រុមហ៊ុនពាណិជ្ជកម្មថ្នាំកសិកម្ម និងជីកសិកម្ម ចំនួន ១៥ក្រុមហ៊ុន
- បានចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មខេត្តគោលដៅចំនួន ២ខេត្ត គឺខេត្តសៀមរាប និងខេត្តឧត្តរមានជ័យលើដេប៉ូចំនួន ៦ដេប៉ូ សម្រេចពិន័យអន្តរការណ៍១ករណី។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- បានតាមដានទិន្នន័យ និងសម្អាត Catch នៅលើ Cloud Server នៃគេហទំព័រទាំង៤១ (ក្រសួង អគ្គនាយកនាយកដ្ឋាន និងមន្ទីររាជធានី-ខេត្ត)

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ និងចុះបណ្តុះបណ្តាលតាមដានការប្រើប្រាស់ និងបង្ហាញមុខងារប្រើប្រាស់ថ្មីៗលើគេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ៦ដូចជា ខេត្តសៀមរាប កំពង់ធំ កំពង់ស្ពឺ កោះកុង តាកែវ និងខេត្តព្រះសីហនុ

- បន្តការធ្វើបច្ចុប្បន្នភាពលើគេហទំព័របណ្ណាល័យកសិកម្ម និងជំរុញការផ្សព្វផ្សាយ និងបណ្តុះបណ្តាលការប្រើ-ប្រាស់អំពីគេហទំព័របណ្ណាល័យកសិកម្ម និងពិនិត្យអំពីការរៀបចំបណ្ណាល័យរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ២គឺខេត្តមណ្ឌលគិរី និងខេត្តរតនគិរី។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានប្រព័ន្ធកសិកម្មតាមរយៈកម្មវិធីផលិតកម្មស្រូវ និងការនាំចេញអង្ករនៅខេត្តបាត់ដំបងមានអ្នកចូលរួមសរុបចំនួន ៣៤នាក់ ស្រី៣នាក់

- បានចុះផលិតវីដេអូបទយកការណ៍ធ្វើការផ្សព្វផ្សាយស្តីពីការចិញ្ចឹមកន្ធាយ កង្កែប(ខេត្តកំពង់ធំ) និងត្រីប្រា ភ្ញាស់-កូនមាន់ (ខេត្តព្រៃវែង) និងបច្ចេកទេសដាំដុះបន្លែសុវត្ថិភាព (ខេត្តសៀមរាប)

- បានចុះទៅថត Video បទយកការណ៍នៅខេត្តក្រចេះ និងខេត្តសៀមរាបចំនួន ២ប្រធានបទមាន៖ ការដាំដំណាំគ្រសក់ ការចិញ្ចឹមកន្ធាយ

- បានចុះផលិតនាទីចុះស្រែជាមួយកសិករចំនួន ២ប្រធានបទមាន៖ ការចងក្រងបណ្តុំកសិករចិញ្ចឹមមាន់ ការចិញ្ចឹម និងបំប៉នគោលក់

- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ៦ដើម្បីចាក់ផ្សាយមាន៖ ការភ្ជួររាស់ពង្រាបដីឱ្យបានស្មើល្អសម្រាប់សាប ព្រោះ ស្រូវនាំរដូវវស្សា ពូជស្រូវកណ្តាលក្រអូបស្រាល (ផ្កាមាលតី) ពូជស្រូវសំខាន់ៗចំនួន ១០ពូជសម្រាប់ផលិត-កម្មស្រូវ និងនាំអង្ករចេញ បច្ចេកទេសដាំដំណាំខាត់ណាផ្កា បច្ចេកទេសស្តីពីការចិញ្ចឹមគោនិងការថែបំប៉នគោជាលក្ខណៈគ្រួសារ បច្ចេកទេសចិញ្ចឹមទាកាប៉ាជាលក្ខណៈគ្រួសារ សម្រាប់ធ្វើការចាក់ផ្សាយនៅស្ថានីយវិទ្យុជាតិ FM105.70.75MHZ នៅថ្ងៃច័ន្ទ និងថ្ងៃព្រហស្បតិ៍ ចាប់ពីម៉ោង ៩:០០នាទី ដល់ម៉ោង ៩:៣០នាទីព្រឹក។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- បានចូលរួមក្នុងពិធីធ្វើបទបង្ហាញអំពីលទ្ធភាពឥណទានដល់កសិករចិញ្ចឹមត្រី មាន់ ទា និងដាំបន្លែជូនប្រជាពលរដ្ឋក្នុងខេត្តកំពត

- បានរៀបចំកិច្ចប្រជុំពិភាក្សាអំពីបញ្ហាប្រឈម និងជំរុញការអនុវត្តការងារផលិតកម្មកសិកម្មតាមកិច្ចសន្យាដែលមានការចូលរួមពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំង២៥រាជធានី-ខេត្ត

- បានសម្របសម្រួល និងរៀបចំពិធីចុះកិច្ចសន្យាផលិតកម្មកសិកម្មការទិញ-លក់ផលិតផលគ្រាប់ស្វាយចន្ទីកែច្នៃ និងការចុះអនុស្សរណៈយោគយល់គ្នារវាងវិស័យសាធារណៈឯកជន ដៃគូអភិវឌ្ឍន៍ និងអ្នកផលិត

- បានចុះពិនិត្យខ្សែចង្វាក់ផលិតកម្មស្វាយចន្ទី និងពិនិត្យវឌ្ឍនភាពនៃគម្រោងសាងសង់រោងចក្រកែច្នៃស្វាយចន្ទីជាមួយអង្គការ TOP Planning នៅខេត្តកំពង់ធំ

- បានចុះប្រជុំផ្សព្វផ្សាយអំពីលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងគោលការណ៍អនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យានៅខេត្តព្រៃវែងដែលមានកសិករចូលរួមចំនួន ៦៥នាក់

- បានរៀបចំបើកវេទិកាប្រជុំចរចាការអនុវត្តផលិតកម្មកសិកម្មតាមកិច្ចសន្យារវាងភាគីអ្នកផលិត និងភាគីអ្នកទិញនៅខេត្តកំពង់ឆ្នាំងដែលមានកសិករចូលរួមចំនួន ៥៥នាក់

- បានចុះបណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំដែលមានកសិករចូលរួមចំនួន ១១០នាក់។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានចូលរួមទិវាពិភពលោកប្រយុទ្ធប្រឆាំងនឹងការធ្លាក់ចុះគុណភាពដី និងគ្រោះរាំងស្ងួតឆ្នាំ២០២០ នៅខេត្តព្រះវិហារ

- បានចុះត្រួតពិនិត្យការងារពិសោធន៍នៅខេត្តតាកែវ

- បានចុះប្រមូលទិន្នន័យស្តីពីការរីកសាយ និងឥទ្ធិពលនៃការទទួលយកបច្ចេកវិទ្យាថ្មីនៅតំបន់ទំនាបនិងខ្ពង់រាបនៅខេត្តក្រចេះ

- បានចុះជ្រើសរើសទីតាំងនិងរៀបចំពិសោធន៍នៅខេត្តសៀមរាប និងខេត្តបាត់ដំបង

- បានចុះដាំពិសោធន៍ និងដាំបង្ហាញម៉ាស៊ីនដាំគ្រាប់ស្ងួតសម្រាប់ស្រូវវស្សានៅខេត្តព្រៃវែង

- បានចុះអនុវត្តការងារពិសោធន៍នៅស្ថានីយកោះកេរ្តិ៍នៅខេត្តព្រះវិហារ

- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការពិនិត្យលើគោលនយោបាយផ្សព្វផ្សាយកសិកម្មនៅខេត្តកំពត។

### **១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម**

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យគឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យា-សាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- គ្រប់មហាវិទ្យាល័យ និងឆ្នាំសិក្សាមូលដ្ឋានបាននិងកំពុងដំណើរការបង្រៀននិស្សិតពីចម្ងាយតាមរយៈប្រព័ន្ធអេ-ឡិចត្រូនិក និងតាមអនឡាញសម្រាប់កម្មវិធីសិក្សាឆមាសទី២ ឆ្នាំសិក្សា ២០១៩-២០២០

- បន្តការងារសិក្សាពិសោធន៍ស្រាវជ្រាវរបស់ខ្លួនលើប្រធានបទមួយចំនួនដូចជាការពិសោធន៍លើចំណីសត្វ ការចិញ្ចឹមសត្វ ពិសោធន៍លើអតិសុខុមប្រាណសាស្ត្រ បរាសិត ការកែច្នៃស្រាព្រីង ការបណ្តុះយីស វិធីសាស្ត្រសម្ងួតល្ហុង ការផលិតម្សៅខ្ទិះ ការស្វែងរកមីក្រូសរីរាង្គនៅក្នុងផលិតផលផ្សេងៗ និងការសិក្សាទំនាក់ទំនងរវាងការធ្វើចំណាកស្រុកនឹងបម្រែបម្រួលនៃប្រព័ន្ធកសិកម្មនិងបរិស្ថាន នៅខេត្តកំពង់ធំនិងតាកែវ

- បានចុះតាមដានប្រព័ន្ធចម្រោះជីវឧស្ម័នតាមបណ្តាកសិដ្ឋានចិញ្ចឹមជ្រូកនៅខេត្តកំពង់ស្ពឺ និងបានចុះទៅដំឡើងឧបករណ៍វាស់វែងគុណភាពឧស្ម័ន និងតម្រូវការភ្លើងនៅរោងចក្រកែច្នៃម្សៅមីនៅខេត្តត្បូងឃ្មុំ។

### **១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប**

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ១ ០៨៨នាក់ (ស្រី៤៥៤នាក់) លើជំនាញ៖ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី

- បានចុះទៅសិក្សាពីដំណាំបន្លែ និងការចិញ្ចឹមសត្វនៅខេត្តកំពត

- បានចុះសិក្សាពីរបៀបវាយតម្លៃគុណភាព និងកំណត់ថ្លៃចន្ទីនៅខេត្តព្រះសីហនុ

- បានចុះសិក្សាពីលទ្ធភាពចុះកម្មសិក្សារបស់និស្សិតចំនួន ៤លើក គឺខេត្តកណ្តាល កំពង់ឆ្នាំង កំពង់ធំ និងខេត្តសៀមរាប

- បន្តការស្រាវជ្រាវលើផ្កាអ័រគីដេ ចេក ស្វាយចន្ទី និងត្រី

- បាននិងកំពុងដំណើរការសាងសង់អគារសម្រាប់ចិញ្ចឹមត្រីឆ្លូក ត្រីដំរី និងមាន់

- បាននិងកំពុងដំណើរការសាងសង់កសិដ្ឋានចិញ្ចឹមគោយកទឹកដោះ។

### **១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម**

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៩-២០២០ សរុបចំនួន ៦៥៦នាក់ (ស្រី២៨៦នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានបញ្ជូននិស្សិតជំនាញវិទ្យាសាស្ត្រកសិកម្មឆ្នាំទី៤ ចំនួន៣នាក់ និងមន្ត្រីចំនួន១នាក់ ចូលរួមជាមួយគម្រោង ERECON លើការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្មនិរន្តរភាព

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- ពិសោធន៍សាកល្បងផលិតមេជី Lacto Bacellus និងពិសោធន៍ឥទ្ធិពលមេជីលើការលូតលាស់ដំណាំស្ពៃក្តោប និងស្រូវនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការពិសោធន៍លើការចិញ្ចឹមបង្កងពូជអូស្ត្រាលីចំនួន ១៦៥គូ និង២៥០កូន នៅស្ថានីយពិសោធន៍ជលផល

នៃវិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច

- សហការជាមួយ DTRA (Defence Threat Reduction Agency) ក្នុងការបើកវគ្គបណ្តុះបណ្តាលចំនួន ៣វគ្គ ដូចជាជំងឺប៉ារ៉ាស៊ីតសត្វឆ្លងមកមនុស្សនៅកម្ពុជា អេពីដេមីសាស្ត្រនៃជំងឺផ្តាសាយបក្សី ជីវសុវត្ថិភាពសម្រាប់ជំងឺហ្សូណូស និងជំងឺសត្វឆ្លងដែនដល់និស្សិតជំនាញវិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រនៅវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម។

### ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- អង្កេតជំងឺលើគ្រប់ឡូត៍ពិសោធន៍កូននៅក្នុងស្ថានីយ
- ថែទាំកូនកៅស៊ូស៊ីដលីង ច្បារបង្កាត់ពូជ និង GSET02
- ត្រួតពិនិត្យការចៀរជ័រ និងការសាប្រមូលផលទឹកជ័រតាមពិធីសារពិសោធន៍គ្រប់ចម្ការពិសោធន៍
- វិភាគរកស្តង់ដាសរីរសាស្ត្រទឹកជ័រលើប៉ារ៉ាម៉ែត្រ Inorganic Phosphorus (Pi) Sucrose (Suc) និង Thiol
- រៀបចំចម្ការពិសោធន៍សាកល្បងការប្រើប្រាស់ជី និងថ្នាំរំញោចដើម្បីបង្កើនទិន្នផលជ័រកៅស៊ូ និងការសាកល្បងការចៀរជ័រដោយម៉ាស៊ីន Tapping Machine
- បាញ់ថ្នាំ Dithan M45 កូនកៅស៊ូតូច (mini budding) ការពារ និងព្យាបាលជំងឺ
- ដាំជួសកូនកៅស៊ូឆ្នាំ ២០១៨-២០១៩ នៅប្លុក 42BNW និង 42BNE
- វាស់ទំហំដើមសម្រាប់បើកមុខចៀរជ័រ ដូចជាលាបថ្នាំរំញោច និងលាបខ្លាញ់គោលើដើមកៅស៊ូចៀរជ័រ
- បានបញ្ចប់ការធ្វើតេស្តជ័រពិសោធន៍ចំនួន ៥៤សំណាកលើអាស៊ីតបីប្រភេទ (អាស៊ីតស៊ុលផួរិក អាស៊ីតហ្វ័រមិក និងម្យៅអាស៊ីត) របស់និស្សិតសរសេរសារណាបទបញ្ចប់ការសិក្សានៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាធ្វើការដាំដុះបានចំនួន ២ ២៨១ ៩២១ហ.ត ស្មើនឹង៨៨,១៧% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត។ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទះជំងឺ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែនតែនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មនៅក្នុងរដូវវស្សាឆ្នាំ២០២០
- បន្តធ្វើការពិនិត្យសន្និធិស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលអានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផល

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

## ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- បន្តអនុវត្តការបង្កាត់ពូជគោ និងជ្រូកដោយសិប្បនិម្មិត។

## ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើឲ្យចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឲ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋាន ឲ្យយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កផ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

## ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្ដីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្ដាអង្គភាពក្រោមឱវាទនិងបណ្ដាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្ដាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្ដែង រួមទាំងការរៀបចំវគ្គបណ្ដុះបណ្ដាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ៕

ថ្ងៃអង្គារ ១៥កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**